# ការលើកកម្ពស់សុខភាពសិក្សាគ្រប់ជ្រុងជ្រោយ នៅសាលាបឋមសិក្សាចតុមុខ

ធ្វើបទបង្ហាញដោយ ៖ លោក សូ ធី

តួនាទី៖ នាយកសាលាបឋមសិក្សាចតុមុខ

ថ្ងៃសុក្រ ២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤

# មាតិកា

១. ស្ថានភាពទូទៅ

២. ការអនុវត្តសកម្មភាពសុខភាពសិក្សាគ្រប់ជ្រុងជ្រោយនៅសាលាបឋមសិក្សាចតុមុខ

៣. បញ្ហាប្រឈម

៤. ទិសដៅបន្ត

# ១. ស្ថានភាពទូទៅ

## មានទីតាំងស្ថិតនៅ ភូមិ១០ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាប់ខាងលិចព្រះបរមរាជវាំង។



# ១. ស្ថានភាពទូទៅ (ត)

ជាសាលាទី១ដែលបានបើកបរវេសនកាលជាប្រវត្តិសាស្ត្រក្រោយថ្ងៃរំដោះ ៧មករា ១៩៧៩ ដោយលោកប្រធាន **ហេង សំរិន** ប្រធានក្រុមប្រឹក្សារដ្ឋ នៃសាធារណៈ ប្រជាមានិតកម្ពុជា។






ពិធីសម្ពោធបើកបវេសនកាលជាផ្លូវការ និងជាប្រវត្តិសាស្ត្រ ថ្ងៃទី២៤ កញ្ញា ១៩៧៩

## ១. ស្ថានភាពទូទៅ (ត)

មានអគារសិក្សាចំនួន ៥ ចែកចេញជា៤២បន្ទប់។



# ១. ស្ថានភាពទូទៅ (ត)

ក្រៅពីបន្ទប់រៀន យើងមានបន្ទប់ជំនាញរោងជាង កសិកម្ម គេហៈ បណ្ណាល័យ ភាសា កុំព្យូទ័រ ស្ទែម និងបន្ទប់សុខភាព។










# ២. ការអនុវត្តលក្ខភាព សុខភាពសិក្សាគ្រប់ជ្រុងជ្រោយ

# ២.១- អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ

➢ បង្កើតគណៈកម្មការសុខភាពសិក្សា



## ២.១- អតិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ (ត)

- រៀបចំក្រុមប្រឹក្សាកុមារដោយមានភារកិច្ចការងារសុខភាពសិក្សា





ការប្រជុំអនុម័ត ពីផែនការបន្តរបស់
ក្រុមប្រឹក្សាកុមារ

# ២.១- អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ ( ត )

➢ រៀបចំបទបញ្ជាផ្ទៃក្នុងរបស់សាលាដោយដាក់បញ្ចូលនូវការងារសុខភាពនិងអនាម័យ





## ២.១- អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ (ត)

➢ រៀបចំបន្ទប់សុខភាព និងចាត់តាំងគ្រូទទួលបន្ទុកសុខភាពសិក្សាប្រចាំការរាល់ម៉ោងធ្វើការ។






## ២.២- ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សានិងបុគ្គលិកអប់រំ

- ពិនិត្យសុខភាព កាយសម្បទា និងសហការជាមួយមណ្ឌលសុខភាពក្នុងការផ្តល់ថ្នាំទម្លាក់ដង្កូវព្រូនដល់សិស្ស២ដង ក្នុង១ឆ្នាំ







# ២.២- ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សានិងបុគ្គលិកអប់រំ (ត)

- សហការជាមួយសាកលវិទ្យាល័យពុទ្ធិសាស្ត្រក្នុងការពិនិត្យនិងព្យាបាលមាត់ធ្មេញសិស្ស២ដង ក្នុង១ឆ្នាំ



## ២.២- ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សានិងបុគ្គលិកអប់រំ ( ត )

- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាទាក់ទងនឹងការគ្រប់គ្រងស្ថានភាពអាហារូបត្ថម្ភ និង វាស់គំហើញរបស់សិស្សានុសិស្សទាំងអស់។

ស្ថានភាពអាហារូបត្ថម្ភ ( សិស្សសរុប1622នាក់/ស្រី814នាក់ )






## ២.៣- ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ

- រៀបចំអាហារដ្ឋាននិងកន្លែងលក់ដូរចំណីអាហារស្របតាមការណែនាំរបស់ក្រសួង
- ហាមឃាត់ការលក់ដូរចំណីអាហារដែលប៉ះពាល់ដល់សុខភាពសិស្ស





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១៨ អយក.សណន

សេចក្តីណែនាំ
ស្តីពី
ការពង្រឹងវិធានការអនុវត្តការលើកកម្ពស់សុវត្ថិភាពនិងសុខុមាលភាពចំណីអាហារ
នៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈនិងឯកជន


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
យុទ្ធនាការផ្សព្វផ្សាយអំពី សុវត្ថិភាពចំណីអាហារនៅក្នុងសាលារៀន

# ២.៣- ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ (ត)

- បិទស្លាកប៉ាណូនិងខិតបណ្ណពាក់ព័ន្ធនឹងសុវត្ថិភាពចំណីអាហារ






## ២.៣- ការលើកកម្ពស់ការផ្ដល់អាហារូបត្ថម្ភ (ត)

- រៀបចំសួនបន្លែវិលជុំនិងសួនជីវៈចម្រុះសម្រាប់លើកកម្ពស់ការយល់ដឹងពីអាហារូបត្ថម្ភ





## ២.៣- ការលើកកម្ពស់ការផ្ដល់អាហារូបត្ថម្ភ (ត)

- ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ និងកម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា

## សាវតារ

កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ និងកម្មវិធីផ្តល់អាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សាតាមសាលារៀនជាផ្នែកមួយនៃកម្មវិធីជំនួយសង្គមរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានចែងក្នុងក្របខណ្ឌ គោនយោបាយជាតិស្តីពីកិច្ចគាំពារសង្គម(២០១៦-២០២៥)។

## ២.៣- ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ (ត)

### គោលបំណង

- កម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា មានគោលបំណងដើម្បីរួមចំណែកបង្កើនវត្តមានការសិក្សា កាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស បង្កើនអត្រាបញ្ចប់ការសិក្សាយ៉ាងហោចណាស់នៅកម្រិតអប់រំមូលដ្ឋាន តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភ ដើម្បីរក្សាភាពគង់វង្សក្នុងការសិក្សារបស់សិស្សក្រីក្រនៅសាលារៀន កុមារងាយរងគ្រោះ និងបាត់បង់ឱកាសឱ្យទទួលបានការសិក្សាប្រកបដោយសមធម៌។
- កម្មវិធីផ្តល់អាហារតាមសាលារៀន មានគោលបំណង ផ្សារភ្ជាប់ការផ្តល់អាហារតាមសាលារៀន ទៅនឹងការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានការអប់រំ, ការទទួលទានអាហារមានជីវជាតិ, សុខុមាលភាពកុមារ និងការអភិវឌ្ឍន៍ជនបទ។ ផ្តោតសំខាន់លើសសរស្តម្ភបួន៖ ✦ការអប់រំ ✦សុខភាព និងអាហារូបត្ថម្ភ ✦វិស័យកសិកម្ម ✦កិច្ចគាំពារសង្គម

# ២.៣- ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ (ត)

## ក). វឌ្ឍនភាពនៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន

**អំឡុងឆ្នាំ១៩៩៩**

ចាប់ផ្តើម ៦៤សាលា អ្នកទទួលផល ៣៧,៥០០ នាក់ និងបានពង្រីកគោលដៅជាបន្តបន្ទាប់

**២០១៥-២០១៨**

ការអនុវត្តសាកល្បងកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍

**២០១៨-២០១៩**

ទទួលអនុវត្តសាកល្បងដោយក្រសួង និងដោយប្រើថវិកាកម្មវិធីស្បៀងអាហារពិភពលោកនៅខេត្តស្ទឹងត្រែង

**២០១៩ -២០២០**

ប្រកាសអនុវត្តជាកម្មវិធីជាតិ ផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍, ប្រើថវិការាជរដ្ឋាភិបាល (**៥ ខេត្ត មាន ២០៥ សាលា**)

**២០២១-២០២២**

ទទួលយកគោលដៅ៨៥ សាលា (កំពង់ឆ្នាំង ១០ ពោធិ៍សាត់ ៨ សៀមរាប ៤៦ ឧត្តរមានជ័យ ២១) សរុបកើនដល់ **២៩០** សាលា

**២០២២-២០២៣**

បន្តទទួលយកគោលដៅ ១៣៧ សាលា (កំពង់ឆ្នាំង ៥៤ កំពង់ធំ ៨៣) **សរុបកើនដល់ ៤២៧ សាលា**

**២០២៣-២០២៤**

ត្រៀមទទួលយកគោលដៅ ១២៦ សាលា (កំពង់ឆ្នាំង ១៩ កំពង់ធំ ៤០ និងសៀមរាប ៦៧) **សរុបកើនដល់ ៥៥៣សាលា**

# ២.៣- ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ ( ត )

## ខ ). វឌ្ឍនភាពនៃការអនុវត្តកម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា



# ២.៣- ការលើកកម្ពស់ការផ្តល់អាហាររូបត្ថម្ភ (ត)

## គ). កម្មវិធីផ្តល់អាហារតាមសាលារៀន

➢ កម្មវិធីផ្តល់អាហារតាមសាលារៀន(រាជរដ្ឋាភិបាល)

| ល.រ | ឆ្នាំសិក្សា | # សាលា បានអនុវត្ត | ចំនួនសិស្សសរុប | | ចំនួនសិស្សហូប | | អ្នកចម្អិន | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | 2019-2020 | 205 | 52,130 | 25,544 | 52,130 | 25,544 | 457 | 366 |
| ២ | 2020-2021 | 205 | 53,675 | 26,301 | 53,589 | 25,325 | 476 | 381 |
| ៣ | 2021-2022 | 290 | 74,877 | 36,212 | 57,471 | 35,369 | 761 | 609 |
| ៤ | 2022-2023 | 427 | 110,281 | 55,272 | 89,059 | 38,690 | 1,122 | 898 |

➢ កម្មវិធីផ្តល់អាហារតាមសាលារៀន(កម្មវិធីស្បៀងអាហារពិភពលោក)

| ល.រ | ឆ្នាំសិក្សា | # សាលា បានអនុវត្ត | ចំនួនសិស្សសរុប | | ចំនួនសិស្សហូប | | អ្នកចម្អិន | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | 2019-2020 | 908 | 223,954 | 109,737 | 167,966 | 82,300 | 1673 | 1,338 |
| ២ | 2020-2021 | 908 | 223,954 | 109,737 | 167,966 | 82,300 | 1673 | 1,338 |
| ៣ | 2021-2022 | 823 | 203,640 | 99,784 | 215,318 | 104,529 | 1,503 | 1,214 |
| ៤ | 2022-2023 | 686 | 173,008 | 84,774 | 178,726 | 86,556 | 1,212 | 973 |

## ២.៣- ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ ( ត )

### ឃ ). កម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា

| ល.រ | ឆ្នាំសិក្សា | #សាលា សរុប | # សាលា បានអនុវត្ត | # សិស្សថ្នាក់ | | សរុបរួម | ភាគរយ កំណើន |
|---|---|---|---|---|---|---|---|
| | | | | ទី១-ទី៣ | ទី៤-ទី៦ | | |
| ១ | 2014-2015 | 7,051 | 2,934 | 0 | 68,234 | 68,234 | - |
| ២ | 2015-2016 | 7,085 | 3,253 | 0 | 77,654 | 77,654 | 13.8 |
| ៣ | 2016-2017 | 7,144 | 4,453 | 0 | 86,126 | 86,126 | 10.9 |
| ៤ | 2017-2018 | 7,189 | 4,611 | 0 | 96,507 | 96,507 | 12.1 |
| ៥ | 2018-2019 | 7,228 | 4,951 | 5,000 | 105,156 | 110,156 | 14.1 |
| ៦ | 2019-2020 | 7,282 | 5,572 | 9,500 | 112,728 | 122,228 | 11 |
| ៧ | 2020-2021 | 7,304 | 5,962 | 31,470 | 117,107 | 148,577 | 17.7 |
| ៨ | 2021-2022 | 7,306 | 5,966 | 35,612 | 113,289 | 148,901 | 0.21 |
| ៩ | 2022-2023 | 7,338 | 5,966 | 35,612 | 113,289 | 148,901 | - |

## ២.៣- ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ (ត)

### ង). ទិសដៅបន្ត

- ទទួលយកសាលារៀនគោលដៅបន្ថែមចំនួន ១២៦សាលា (កំពង់ឆ្នាំង១៩ កំពង់ធំ៤០ និងសៀមរាប៦៧) ពីកម្មវិធីស្បៀងអាហារពិភពលោក មកអនុវត្តជាកម្មវិធីជាតិ សរុប ៥៥៣សាលា
- បន្តពង្រឹងសមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រង និងដឹកនាំកម្មវិធីដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- បន្តចុះពង្រឹងការអនុវត្តកម្មវិធីនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលាគោលដៅ ឱ្យកាន់តែមានប្រសិទ្ធភាព។

# ២.៨- ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ

- រៀបចំបង្គន់អនាម័យ និងកន្លែងលាងសម្អាតដៃជាក្រុមច្រើនកន្លែង ដោយមានសាប៊ូជាប្រចាំ






## ២.៨- ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ (ត)

- រៀបចំឱ្យមានទឹកសម្រាប់ទទួលទាន បណ្ដាយទឹកស្អាតសម្រាប់ប្រើប្រាស់ និងសម្អាតជាប្រចាំ

ការប្រើប្រាស់ទឹក
មានសុវត្ថិភាព



និងការសម្អាតជាប្រចាំ







# ២.៨- ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ (ត)

➢ រៀបចំធុងសំរាម និងទុកដាក់សំរាមតាមលក្ខណៈបច្ចេកទេស។



## ២.៨- ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព

- រៀបចាក់សាបតាមទីធ្លា សួនផ្កា ដើមរុក្ខជាតិសម្រាប់លម្អ ទីលានហាត់ប្រាណ កន្លែងលេងកីឡា



## ២.៨- ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព (ត)

- រៀបចំកន្លែងលេងកំសាន្តសម្រាប់កុមារ របសំណាក និងគ្រឿងលម្អបរិស្ថាន។





# ២.៦- ការលើកកម្ពស់សន្តិសុខនិងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា

- រៀបចំក្រុមប្រឹក្សាកុមារដើម្បីយាមច្រកចេញចូលគ្រប់ពេលម៉ោងសិក្សា






# ២.៦- ការលើកកម្ពស់សន្តិសុខនិងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា (ត)

- រៀបចំជួសជុលទ្វាររបងសាលា កន្លែងផ្ញើយានយន្ត បំពង់ពន្លត់អគ្គីភ័យ






## ២.៦- ការលើកកម្ពស់សន្តិសុខនិងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា (ត)

- រៀបចំឱ្យមានលេខទូរស័ព្ទទំនាក់ទំនងសំខាន់ៗទៅអ្នកពាក់ព័ន្ធសម្រាប់ចុះអន្តរាគមន៍បន្ទាន់
- សហការជាមួយអាជ្ញាធរមូលដ្ឋានធ្វើចរាចរណ៍មុខសាលារៀនពេលសិស្សចេញទៅផ្ទះ។



# ២.៧- ការលើកកម្ពស់ការអប់រំសុខភាព

➢ រៀបចំផែនការបង្រៀននិងកាលវិភាគបង្រៀនមុខវិជ្ជាអប់រំសុខភាព ១ម៉ោងក្នុង១សប្តាហ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ
ការិយាល័យអប់រំយុវជន និងកីឡាខណ្ឌដូនពេញ
សាលាបឋមសិក្សា ចតុមុខ

ឆ្នាំសិក្សា: ២០២១-២០២២

## ផែនការអប់រំសុខភាពប្រចាំឆ្នាំសម្រាប់ថ្នាក់ទី៤

| ខែ | ខ្លឹមសារ | ចំនួនម៉ោង | ស/ស | ស/គ | ហ្វីស |
|---|---|---|---|---|---|
| មករា ៣ម៉ | **សមាសភាគទី១. សុខភាពបឋម** | | ៦ | ១ | |
| | **ជំពូកទី១ ការលូតលាស់ និង អាហារូបត្ថម្ភ** | | ៦ | ១ | |
| | មេរៀនទី១ លំហាត់ប្រាណ | | ៦ | ១ | |
| | ១.លំហាត់ប្រាណ និងការលូតលាស់ | ១ | ៦ | ១ | ១ |
| | ២.សារសំខាន់នៃអាហារ និងលំហាត់ប្រាណទៀងទាត់ | ១ | ៨ | ៤ | ២ |
| | មេរៀនទី២ ពីរ៉ាមីតអាហារ | | ១០ | ៧ | |
| | ១.ពីរ៉ាមីតអាហារ | ១ | ១០ | ៧ | ៣ |
| | ២.សារសំខាន់នៃការបរិភោគតាមពីរ៉ាមីតអាហារ | | ១២ | ៧ | |
| កុម្ភៈ ៤ម៉ | ៣.សារគន្លឹះទាំង៧ | ១ | ១៣ | ១៣ | ៤ |
| | មេរៀនទី៣ សារធាតុចិញ្ចឹម | | ១៦ | ២០ | |
| | ១.មូលដ្ឋានគ្រឹះនៃសារធាតុចិញ្ចឹម | ១ | ១៧ | ២៣ | ៥ |
| | ២.សារសំខាន់នៃសារជាតិចិញ្ចឹមនីមួយៗ | ១ | ២១ | ២៧ | ៦ |
| | **ជំពូកទី២ អនាម័យខ្លួនប្រាណ និង អនាម័យទូទៅ** | | ២៤ | ៣១ | |
| | មេរៀនទី១ ការសម្អាតរាងកាយ | | ២៤ | ៣១ | |
| | ១.ការសម្អាតដៃ | ១ | ២៥ | ៣១ | ៧ |
| មីនា ៤ម៉ | ២.ការសម្អាតជើង | ១ | ២៦ | ៣៥ | ៨ |
| | មេរៀនទី២ ការថែទាំបង្គន់ | | ២៧ | ៣៨ | |
| | ១ការប្រើប្រាស់ និងថែទាំបង្គន់ | ១ | ២៧ | ៣៨ | ៩ |
| | ២ការសម្អាតបង្គន់ | ១ | ៣០ | ៤៣ | ១០ |
| | **ជំពូកទី៣ ការថែទាំភ្នែក និង មាត់ធ្មេញ** | | ៣២ | ៤៦ | |
| | មេរៀនទី១ ការថែទាំអញ្ចាញធ្មេញ | | ៣២ | ៤៦ | |



| ខែ | ខ្លឹមសារ | ចំនួនម៉ោង | ស/ស | ស/គ | ហ្វីស |
|---|---|---|---|---|---|
| | ១.ជំងឺអញ្ចាញធ្មេញ | ១ | ៣២ | ៤៦ | ១១ |
| មេសា ៣ម៉ | ២.ការថែទាំអញ្ចាញធ្មេញ | ១ | ៣៣ | ៤៩ | ១២ |
| | មេរៀនទី២ ជំងឺរលាកអញ្ចាញធ្មេញ | | ៣៥ | ៥១ | |
| | ១.រោគសញ្ញាជំងឺរលាកអញ្ចាញធ្មេញ | ១ | ៣៥ | ៤៦ | ១៣ |
| | ២.ផលវិបាកជំងឺរលាកអញ្ចាញធ្មេញ | | ៣៦ | ៥១ | |
| | ៣.ការបង្ការជំងឺរលាកអញ្ចាញធ្មេញ | ១ | ៣៧ | ៥៦ | ១៤ |
| ឧសភា ៣ម៉ | មេរៀនទី៣ របួសភ្នែក | ១ | ៣៩ | ៥៩ | ១៥ |
| | **ជំពូកទី៤ ជំងឺឆ្លងដោយសារមូស** | | ៤២ | ៦៣ | |
| | មេរៀនទី១ ជំងឺគ្រុនចាញ់ | | ៤២ | ៦៣ | |
| | ១.មូលហេតុនៃជំងឺគ្រុនចាញ់ | ១ | ៤២ | ៦៣ | ១៦ |
| | ២.រោគសញ្ញាជំងឺគ្រុនចាញ់ | | ៤៣ | | |
| | ៣.វិធីបង្ការជំងឺគ្រុនចាញ់ | ១ | ៤៣ | ៦៦ | ១៧ |
| | ៤.ការស្វែងរកសេវាព្យាបាល | | ៤៤ | | |
| មិថុនា ៣ម៉ | មេរៀនទី២ ជំងឺគ្រុនឈាម | | ៤៦ | ៦៩ | |
| | ១.មូលហេតុនៃជំងឺគ្រុនឈាម<br>២.រោគសញ្ញាជំងឺគ្រុនឈាម | ១ | ៤៦ | ៦៩ | ១៨ |
| | ៣.វិធីបង្ការជំងឺគ្រុនឈាម<br>៤.ការស្វែងរកសេវាឈាម | ១ | ៤៧ | ៧២ | ១៩ |
| | **សមាសភាគទី២ សុខភាពផ្លូវចិត្ត** | | ៤៩ | ៧៥ | |
| | មេរៀនទី១ ការតានតឹងចិត្ត | | ៤៩ | ៧៥ | |
| | ១.ការតានតឹងចិត្ត | ១ | ៤៩ | ៧៥ | ២០ |
| កក្កដា ៥ម៉ | ២.មូលហេតុនៃការតានតឹងចិត្ត | ១ | ៤៩ | ៧៩ | ២១ |
| | ៣.ផលវិបាកនៃការតានតឹងចិត្តមកលើសុខភាព | | ៥១ | ៧៩ | |
| | មេរៀនទី២ ការគ្រប់គ្រងការតានតឹងចិត្ត | | ៥០ | ៧៧ | |
| | ១.ឥរិយាបថអវិជ្ជមានពេលតានតឹងចិត្ត | ១ | ៥៣ | ៨៤ | ២២ |
| | ២.វិធីទប់ទល់ការតានតឹងចិត្ត | ១ | ៥៣ | ៨៧ | ២៣ |
| | ៣.វិធីដោះស្រាយការតានតឹងចិត្ត | | ៥៣ | ៨៧ | |
| | មេរៀនទី៣ ការប្រែប្រួលអារម្មណ៍នៅវ័យជំទង់ | | ៥៣ | ៨២ | |
| | ១.ការប្រែប្រួលអារម្មណ៍ពេលចូលវ័យជំទង់ | ១ | ៥៦ | ៩០ | ២៤ |
| | ២.ការគ្រប់គ្រងអារម្មណ៍ពេលឈានចូលវ័យជំទង់ | ១ | ៥៨ | ៩៤ | ២៥ |



| ខែ | ខ្លឹមសារ | ចំនួនម៉ោង | ស/ស | ស/គ | ហ្វីស |
|---|---|---|---|---|---|
| សីហា ៤ម៉ | **សមាសភាគទី៣ សុខភាព និង បរិស្ថាន** | | ៦០ | ៩៨ | |
| | មេរៀនទី១ ការចៀសចេញពីស្ថានភាពគ្រោះថ្នាក់ | ១ | ៦០ | ៩៨ | ២៦ |
| | មេរៀនទី២ សុវត្ថិភាពពេលភ្លៀង | | ៦២ | ១០២ | |
| | ១.គ្រោះថ្នាក់ពេលភ្លៀង | ១ | ៦២ | ១០២ | ២៧ |
| | ២.វិធីបង្ការគ្រោះថ្នាក់ពេលភ្លៀង | ១ | ៦២ | ១០៥ | ២៨ |
| | មេរៀនទី៣ សុវត្ថិភាពពេលទឹកជំនន់ | | ៦៦ | ១០៨ | |
| | ១.គ្រោះថ្នាក់ពេលទឹកជំនន់ | ១ | ៦៦ | ១០៨ | ២៩ |
| កញ្ញា ៣ម៉ | ២.វិធានការនៅពេលទឹកជំនន់ | ១ | ៦៧ | ១១១ | ៣០ |
| | ៣.អនាម័យពេលទឹកជំនន់ | | ៦៨ | ១១១ | |
| | មេរៀនទី៤ ការលង់ទឹក | | ៧០ | ១១៥ | |
| | ១.មូលហេតុនៃការលង់ទឹក | ១ | ៧០ | ១១៥ | ៣១ |
| | ២.ស្ថានភាពនៃការលង់ទឹក | ១ | ៧១ | ១១៨ | ៣២ |
| តុលា ៣ម៉ | ៣.វិធានការបង្កានៃការលង់ទឹក | ១ | ៧១ | ១២១ | ៣៣ |
| | មេរៀនទី៥ គ្រោះថ្នាក់នៃការសាកល្បងថ្នាំលេប | ១ | ៧៤ | ១២៤ | ៣៤ |
| | មេរៀនទី៦ សារៈសំខាន់នៃព្រៃឈើចំពោះសុខភាព | ១ | ៧៦ | ១២៧ | ៣៥ |

◇◇◇ចំពោះម៉ោងប្រឡងអាចយកថ្ងៃណាក៏បានប៉ុន្តែត្រូវស្ថិតនៅក្នុងសប្តាហ៍ទី៤រៀងរាល់ខែតាមភាពជាក់ស្តែងរបស់សាលានីមួយៗ

ថ្ងៃ អង្គារ ០៩ កើត ខែ បុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២
ប្រធានក្រុមបច្ចេកទេស

**បានឃើញ និងឯកភាព**
**ជ-នាយកសាលា**
**_នាយករងទទួលបន្ទុកបឋម**

កែវ កន្និដ្ឋា

# ២.៧- ការលើកកម្ពស់ការអប់រំសុខភាព (ត)

- សហការបំប៉នសមត្ថភាពគ្រូពីការអប់រំសុខភាពស្របតាមការវិវត្តនៃសុខភាពសាធារណៈ



## ២.៧- ការលើកកម្ពស់ការអប់រំសុខភាព (ត)

➢ ណែនាំសិស្សរៀងរាល់ពេលគោរពទង់ជាតិ នូវការរក្សាអនាម័យនិងថែទាំសុខភាព។



# ២.៨-ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព

- រៀបចំការលាងសម្អាតដៃនិងដុសសម្អាតធ្មេញជាក្រុមរៀងរាល់ថ្ងៃ








## ២.៨-ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព (ត)

- រៀបចំការលាងសម្អាតបង្គន់អនាម័យ កន្លែងលាងសម្អាតដៃ បន្ទប់រៀន និងទីធ្លាសាលារៀនជាប្រចាំថ្ងៃ







# ២.៨-ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព (ត)

- រៀបចំក្រុមត្រួតពិនិត្យអនាម័យតាមវេន ដែលដឹកនាំដោយក្រុមប្រឹក្សាកុមារ
- រៀបចំការហាត់ប្រាណបានទៀងទាត់ តាមកាលវិភាគនៃថ្នាក់នីមួយៗ។





## ២.៩-ការលើកកម្ពស់ការចូលរួមគ្រប់ភាគីពាក់ព័ន្ធ

- អាជ្ញាធរមូលដ្ឋាន និងមាតាបិតាក្នុងការចូលរួមសកម្មភាពរបស់សាលា



## ២.៩-ការលើកកម្ពស់ការចូលរួមគ្រប់ភាគីពាក់ព័ន្ធ (ត)

- សហការជាមួយមណ្ឌលសុខភាពក្នុងការពិនិត្យសុខភាព ការផ្ដល់ថ្នាំទម្លាក់ដង្កូវព្រូន និងថ្នាំបង្ការតាមកម្មវិធីជាតិផ្ដល់ថ្នាំបង្ការរបស់ក្រសួងសុខាភិបាល
- សហការជាមួយសាកលវិទ្យាល័យពុទ្ធិសាស្ត្រក្នុងការពិនិត្យនិងព្យាបាលមាត់ធ្មេញ
- សហការជាមួយអង្គការ F ID R ក្នុងការបំប៉នសមត្ថភាពគ្រូពីការអប់រំសុខភាព។





## ២.៩-ការលើកកម្ពស់ការចូលរួមគ្រប់ភាគីពាក់ព័ន្ធ (ត)

- សហការជាមួយវិទ្យាស្ថានស្តារគំហើញ Briden Holden, Fred Hollows Foundation (FHF) និងកម្មវិធីសុខភាពភ្នែកក្នុងការពិនិត្យភ្នែកនិងផ្តល់វ៉ែនតា






## ២.៩-ការលើកកម្ពស់ការចូលរួមគ្រប់ភាគីពាក់ព័ន្ធ (ត)

- សហការជាមួយដៃគូផ្សេងៗទៀតក្នុងការផ្តល់សម្ភារៈអនាម័យ សម្ភារៈរម្ងាប់មេរោគ កន្លែងលាងសម្អាតដៃ បង្គន់អនាម័យ ។ល។ ពិសេសក្នុងបរិបទការរាតត្បាតជំងឺកូវីដ១៩ សាលាបានទទួល សម្ភារៈនិងឯកសារពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ជំងឺកូវីដ១៩បានទាន់ពេលវេលា។







# ៣. បញ្ហាប្រឈម

៣.១- សាលាពុំទាន់មានត្រាមូលសម្រាប់ប្រើប្រាស់
៣.២- ការលក់ដូរចំណីអាហារពុំមានសុវត្ថិភាពនៅជុំវិញសាលារៀន
៣.៣- សាលានៅខ្វះសៀវភៅតាមដានសុខភាព និងសៀវភៅអប់រំសុខភាព



ការរៀបចំឯកសារពាក់ព័ន្ធសុខភាព

# ៨. ទិសដៅបន្ត

សាលានឹងបន្តអនុវត្តយុទ្ធសាស្ត្រទាំង៩ នៃគោលនយោបាយជាតិស្តីពីសុខភាពសិក្សា តាមរយៈ ៖

- ការធ្វើបច្ចុប្បន្នភាពលើឯកសារគតិយុទ្ធ បទបញ្ញត្តិផ្ទៃក្នុង
- បន្តកិច្ចដំណើរការបន្ទប់សុខភាព ការវាស់កម្ពស់ ថ្លឹងទម្ងន់ វាស់គំហើញ
- ផ្តល់សេវាពិនិត្យសុខភាព និងការអប់រំសុខភាព
- លើកកម្ពស់អាហារូបត្ថម្ភ សួនដំណាំ ទឹកស្អាតនិងអនាម័យ លើកកម្ពស់បរិស្ថាន និងលើកកម្ពស់សន្តិសុខនិងសណ្តាប់ធ្នាប់ ដើម្បីប្រែក្លាយសាលារៀន១ជាតំបន់សុខសាន្ត១
- ការលើកកម្ពស់បំណិនសុខភាព និងការគៀរគរឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធសំដៅលើកកម្ពស់កម្មវិធីសុខភាពសិក្សានៅតាមសាលារៀន។

# សំណួរ និងចម្លើយ




សូមអរគុណ!

